# សម្រង់សេចក្តីសង្ខេបអំពីការស្នើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព (SPM)

សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) គឺជាអង្គការអន្តររដ្ឋាភិបាលមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧០ ដែលមានសមាជិកចំនួន ១៣ប្រទេស ក្នុងនោះរួមមាន បង់ក្លាដែស កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ប៉ាពួញូហ្គីណេ ហ្វីលីពីន សិង្ហបុរី ស្រីលង្កា ថៃ និង វៀតណាម។ សមាគមនេះជាវេទិកាអន្តរជាតិសម្រាប់ការវិភាគ និងបង្កើតគោលនយោបាយលើបញ្ហាទាក់ទងនឹងផលប្រយោជន៍រួមរបស់អ្នកផលិតកៅស៊ូធម្មជាតិនៅក្នុងបណ្តាប្រទេសសមាជិក។

បេសកកម្មរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ANRPC គឺបន្តលើកកម្ពស់ផលិតភាពកៅស៊ូ កាត់បន្ថយថ្លៃដើម បង្កើនតម្លៃបន្ថែមក្នុងវិស័យកៅស៊ូផ្នែកលំហូរក្រោម (ផលិតផលកៅស៊ូធម្មជាតិ) ស្វែងរកប្រភពចំណូលបន្ថែម ទាញយកប្រយោជន៍ពីគុណភាពកៅស៊ូធម្មជាតិដែលមិនប៉ះពាល់ដល់បរិស្ថាន និងការពារជីវភាពកសិករដាំកៅស៊ូ។

ANRPC កំពុងស្ថិតក្នុងដំណើរនៃការសិក្សាយន្តការមួយដើម្បីដោះស្រាយថ្លៃកៅស៊ូធម្មជាតិ ដែលកំពុងមានតម្លៃទាប និងដើម្បីធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងខ្សែច្រវ៉ាក់តម្លៃទាំងមូលនៃឧស្សាហកម្មកៅស៊ូធម្មជាតិ គិតចាប់ពីផ្នែកខាងលើរហូតដល់ផ្នែកខាងក្រោមក្នុងរយៈពេលយូរ និងការពារផលប្រយោជន៍របស់អ្នកពាក់ព័ន្ធក្នុងឧស្សាហកម្មកៅស៊ូធម្មជាតិ។

ដើម្បីឲ្យមានការសម្រេចចិត្តកាន់តែប្រសើរឡើង ANRPC សូមប្រមូលមតិកែលម្អពីភាគីពាក់ព័ន្ធក្នុងវិស័យកៅស៊ូ ធម្មជាតិលើយន្តការថ្លៃដែលបានស្នើឡើងក្នុងការបង្កើតគម្លាតថ្លៃអប្បរមានិងអតិបរមា។ ដូច្នេះហើយ យើងសូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលា និងការយកចិត្តទុកដាក់របស់លោកអ្នកក្នុងការផ្តល់ការឆ្លើយតបដ៏មានតម្លៃរបស់អ្នកលើសំណើ ដោយធ្វើបែបនេះងាយស្រួលវាយតម្លៃនិងសិក្សាក្នុងការស្នើបង្កើតយន្តការថ្លៃប្រកបដោយនិរន្តរភាព មួយវិញទៀត វាក៏ជាព័ត៌មានសង្ខេបអំពីយន្តការថ្មីដែលផ្តួចផ្តើមដោយ ANRPC យន្តការថ្លៃប្រកបដោយនិរន្តរភាព (SPM)។

## ១.ប្រវត្តិនៃការស្នើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព

ការស្នើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព គឺជាវិធានការមួយធានាបាននូវឧស្សាហកម្មកៅស៊ូធម្មជាតិដ៏រឹងមាំ និងមាន និរន្តរភាពនៅក្នុងខ្សែច្រវ៉ាក់តម្លៃកៅស៊ូ ជាពិសេសការការពារផលប្រយោជន៍រួមរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យកៅស៊ូ ទាំងកសិករ និងអ្នកផលិត ទទួលបាន នូវតារាងតម្លៃរួមទាំងថ្លៃអប្បបរមា និងថ្លៃអតិបរមា តាមរយៈច្បាប់នៅក្នុងប្រទេសផលិតកៅស៊ូ ។ យន្តការនេះនឹងអាចឲ្យថ្លៃកៅស៊ូផ្លាស់ប្តូរទៅជា

ថ្លៃរួម ដែលបង្ករលក្ខណៈងាយស្រួលកំណត់រួមនៅក្នុងទីផ្សារ។ ការអនុវត្តយន្តការបែបនេះនឹងត្រូវបាន គ្រប់គ្រងក្រោមបទបញ្ញត្តិច្បាប់នៅក្នុងប្រទេសរៀងៗខ្លួន។

## ២.គោលបំណងដែលចង់បាននៃការស្នើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព

-ដើម្បីការពារផលប្រយោជន៍របស់កសិករឲ្យអាចទទួលបានកម្រិតតម្លៃអប្បបរមា ប៉ុន្តែមិនត្រូវលើសពីតម្លៃអតិបរមានោះទេ។

-ដើម្បីការពារផលប្រយោជន៍របស់អ្នកផលិតកៅស៊ូសម្រាប់ការទិញវត្ថុធាតុដើមខ្ពស់ជាងថ្លៃអតិបរមា ប៉ុន្តែមិនតិចជាងថ្លៃអប្បបរមា។

-ដើម្បីកាត់បន្ថយការប្រែប្រួលតម្លៃកៅស៊ូធម្មជាតិនៅក្នុងទីផ្សារ ក្នុងកម្រិតថ្លៃដែលបានកំណត់តម្លៃអប្បបរមា និងអតិបរមា។

-ដើម្បីធានាបាននូវនិរន្តរភាព និងការប្រកួតប្រជែងក្នុងខ្សែច្រវ៉ាក់តម្លៃនៃវិស័យកៅស៊ូធម្មជាតិ នៅបណ្តាប្រទេសផលិតកៅស៊ូ ទាំងអស់ ប៉ុន្តែមិនកំណត់ចំពោះការធានាការផ្គត់ផ្គង់វត្ថុធាតុដើមគ្រប់គ្រាន់សម្រាប់ភាគីផ្នែកលំហូរក្រោម ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រសម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត កាត់បន្ថយការប្រែប្រួលថ្លៃសម្រាប់ការគ្រប់គ្រងសាច់ប្រាក់កាន់តែប្រសើរឡើងនៅក្នុងផ្នែកខាងលើនិងខាងក្រោម។ វាក៏អាចធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់កសិករជាមួយនឹងកម្រិតជាក់លាក់មួយ និងកាត់បន្ថយភាពក្រីក្ររបស់សិករស្របពេលមានជំងឺរាតត្បាតនេះ។

## ៣.ហេតុអ្វីបានជាយើងត្រូវពិចារណាលើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព?

ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នានៃការសន្ទត់ក្នុងទីផ្សារទំនិញកសិកម្ម ដោយផ្អែកលើចំណុចខាងក្រោម៖

-ទោះបីជាទីផ្សារកៅស៊ូធម្មជាតិ អាចចាត់ទុកថាដំណើរការនេះពឹងផ្អែកលើការប្រកួតប្រជែងទីផ្សារបានល្អឥតខ្ចោះក៏ដោយ ប៉ុន្តែតួអង្គនានាក្នុងឧស្សាហកម្មនេះមិនបានចែករំលែកព័ត៌មានល្អសមហេតុផល/ការចរចាថ្លៃ ឬផលិតផលពីកសិករត្រូវបានបង់ដូចគ្នាដោយគ្មានតម្រូវការនោះឡើយ។

-ហេតុនេះហើយ ជាលទ្ធផលនៃការប្រកួតប្រជែងមិនបានល្អ នៅក្នុងទីផ្សារកៅស៊ូធម្មជាតិ ដែលនាំឲ្យថ្លៃអាចទទួលរងឥទ្ធិពលពីការប្រកួតប្រជែងទីផ្សារផ្តាច់។ ដោយសារការប្រកួតប្រជែងមិនមានភាពល្អឥតខ្ចោះ អ្នកទិញទាំងនេះអាចមានអំណាចចរចាច្រើនជាងអ្នកផលិតនៅក្នុងទីផ្សារសម្រាប់ការកំណត់ថ្លៃ ហើយអាចប៉ះពាល់ដល់ថ្លៃទំនិញ និងសេវាកម្មដែលសមរម្យ។ អ្នកនាំចេញនៅក្នុងប្រទេសនាំចេញមិនមែនជាអ្នកផលិតកៅស៊ូពិតប្រាកដទេ ពួកគេជាពាណិជ្ជករ។

-អ្នកនាំចេញទទួលបានកៅស៊ូធម្មជាតិពីកសិករ និងពាណិជ្ជករក្នុងស្រុក បន្ទាប់មកអាចដំណើរការកែច្នៃមុនពេលនាំចេញ។ ថ្លៃដើមផលិតកម្មសម្រាប់អ្នកនាំចេញរួមមានថ្លៃដើមនៃលទ្ធកម្ម និងថ្លៃប្រតិបត្តិការ/ដំណើរការកែច្នៃ។ ប្រាក់ចំណេញរបស់អ្នកនាំចេញត្រូវបានកំណត់ដោយភាពខុសគ្នារវាងថ្លៃទិញនិងលក់។

-អ្នកប្រមើលមើលក្នុងទីផ្សារអនាគតកៅស៊ូធម្មជាតិ ដើរតួនាទីយ៉ាងសំខាន់ដើម្បីមានឥទ្ធិពលលើថ្លៃកៅស៊ូធម្មជាតិ ។ ពួកគេបង្កើតថ្លៃកៅស៊ូជាចម្បង (ច្រើនជាង៩៩%) តាមរយៈកិច្ចសន្យាទិញ និងលក់កៅស៊ូធម្មជាតិ ដោយមិនមានការដឹកជញ្ជូនផ្ទាល់។ ចលនាថ្លៃកៅស៊ូធម្មជាតិ ប្រចាំថ្ងៃមិនអាស្រ័យលើកត្តាមូលដ្ឋានទីផ្សារ - តម្រូវការ និងការផ្គត់ផ្គង់កៅស៊ូធម្មជាតិនោះទេ ប៉ុន្តែភាគច្រើនផ្តោតធ្ងន់ទៅលើកត្តាខាងក្រៅលើសពីទីផ្សារកៅស៊ូ ដូចជា អត្រាប្តូរប្រាក់ដុល្លារអាមេរិក ទល់នឹងនឹងប្រទេសនាំចេញ/នាំចូល អត្រាការប្រាក់បម្រុងសហព័ន្ធ ទំនោរសេដ្ឋកិច្ចពិភពលោក ការអភិវឌ្ឍន៍នៅក្នុងទីផ្សារប្រេង គោលនយោបាយទាក់ទងនឹងវិស័យកៅស៊ូធម្មជាតិ ដូចជា រថយន្ត យានជំនិះ ការផ្គត់ផ្គង់វេជ្ជសាស្រ្ត និងច្រើនទៀត។

-អ្នកទិញ ឬអ្នកផលិតកៅស៊ូធម្មជាតិធំៗ អាចដើរតួជាអ្នកប្រមើលមើល ឬពាណិជ្ជករនៅក្នុងទីផ្សារអនាគតនៃកៅស៊ូធម្មជាតិ ។ ខណៈពេលដែលអ្នកផលិតកៅស៊ូធម្មជាតិពិតប្រាកដ (កសិករ) មិនដែលចូលរួមក្នុងទីផ្សារអនាគតរបស់កៅស៊ូធម្មជាតិទេ ។ ដូច្នេះហើយ វាបើកផ្លូវមួយទៀតសម្រាប់អ្នកទិញកៅស៊ូធម្មជាតិធំៗ ដែលរមានឥទ្ធិពលលើថ្លៃតាមរយៈទីផ្សារអនាគត។

-ថ្លៃកៅស៊ូធម្មជាតិនៅក្នុងទីផ្សារអនាគត និងថ្លៃកិច្ចសន្យាប្រគល់-ទទួលជាក់ស្តែងគឺទាក់ទងតាមរយៈការអនុវត្តកិច្ចសន្យារយៈពេលវែង (LTC) ។ កិច្ចសន្យារយៈពេលវែង LTC គឺជាកិច្ចសន្យារវាងក្រុមហ៊ុនផលិតភាគច្រើននៅក្នុងប្រទេសនាំចូល និងអ្នកនាំចេញនៅក្នុងប្រទេសផលិត។ វាត្រូវបានប្រើដើម្បីធានាបាននូវបរិមាណដែលបានព្រមព្រៀងគ្នានៃកៅស៊ូ នៅពេលអនាគត ដែលអាចលើសពី ៦០ ថ្ងៃទៅ ១២ខែ គិតចាប់ពីថ្ងៃចុះកិច្ចសន្យា។ ដើម្បីកាត់បន្ថយហានិភ័យតម្លៃក្នុងអំឡុងពេលនេះ ភាគីទាំងពីរជាធម្មតាកំណត់ថ្លៃជាមធ្យមនៅក្នុងទីផ្សារអនាគត ១ខែ មុនខែចែកចាយជាតម្លៃសម្រាប់ការចែកចាយជាក់ស្តែង។ អ្នកនាំចេញប្រើថ្លៃនេះបន្ទាប់ពីកាត់ប្រាក់ចំណេញអប្បបរមាសម្រាប់ការទិញកៅស៊ូពីកសិករ។ ដូច្នេះហើយ កសិករតែងតែជាអ្នកយកថ្លៃក្នុងខ្សែច្រវ៉ាក់តម្លៃ។

-ហេតុផលដែលអាចកើតមានមួយទៀតសម្រាប់ការប្រែប្រួលថ្លៃអាចផ្អែកលើតម្រូវការ និងការផ្គត់ផ្គង់នៃកៅស៊ូធម្មជាតិ ។ ក្នុងបណ្តាឆ្នាំដ៏ល្អ ដែលមានការប្រមូលផលល្អអាចនាំឱ្យមានការផ្គត់ផ្គង់កៅស៊ូធម្មជាតិលើស ជាហេតុធ្វើឱ្យថ្លៃកៅស៊ូធម្មជាតិធ្លាក់ចុះ។ ផ្ទុយទៅវិញ ក្នុងប៉ុន្មានឆ្នាំដែលកង្វះការផ្គត់ផ្គង់ដោយសារការប្រែប្រួលអាកាសធាតុ ឬការកើនឡើងភ្លាមៗនៃតម្រូវការ ដូចជាការងើបឡើងវិញក្រោយកូវីដ១៩ ធ្វើឱ្យថ្លៃ

កៅស៊ូធម្មជាតិកើនឡើងដែលមិនបានរំពឹងទុក។ ដូច្នេះយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព ដែលបានស្នើឡើងក្នុងការកំណត់ថ្លៃអប្បបរមា និងអតិបរមាអាចជួយដោះស្រាយការប្រែប្រួលថ្លៃបាន។

### ៤.យន្តការដែលស្នើឡើងសម្រាប់កំណត់កម្រិតថ្លៃនៃយន្តការថ្លៃប្រកបដោយប្រសិទ្ធភាព (ឧ.ការសម្គាល់ដោយប្រើប្រាស់ថ្លៃផ្ទុកទំនិញចូលនាវានូវកៅស៊ូប្រភេទ TSR-20 , ថ្លៃផ្ទុកទំនិញចូលនាវា)

កម្រិតតម្លៃគោលដៅនៃយន្តការថ្លៃប្រកបដោយនិរន្តរភាពត្រូវបានទាញយកជាចម្បង ដើម្បីគ្របដណ្តប់ប្រហែល ៩០% នៃថ្លៃដើមផលិតកម្មកៅស៊ូប្រភេទ TSR20 សម្រាប់កសិករ ខណៈពេលដែលថ្លៃអតិបរមាត្រូវបានកំណត់ដោយមិនដាក់បន្ទុកដល់វិស័យខាងក្រោមលើការចំណាយខ្ពស់ដែលមិនសមហេតុផលក្នុងការទិញវត្ថុធាតុដើម។ ថ្លៃខុសគ្នារវាងថ្លៃអប្បបរមា និងអតិបរមាគឺ ១៣០ សេនដុល្លារអាមេរិក ដែលកំណត់ផងដែរចំពោះការប្រែប្រួលថ្លៃត្រូវបានកំណត់ត្រឹម ១៣០ សេនដុល្លារអាមេរិក (ឬ ១៣០០ដុល្លារអាមេរិក/តោន) ហើយនេះកាត់បន្ថយការប្រែប្រួលថ្លៃកៅស៊ូផងដែរ ដែលថ្លៃអាចផ្លាស់ប្តូរនៅក្នុងរង្វង់នេះ។ ប្រភេទនិងថ្នាក់ផ្សេងទៀតនៃថ្លៃគោលកៅស៊ូធម្មជាតិអតិបរមានិងអប្បបរមា នឹងត្រូវបានកំណត់ដោយអនុវត្តភាពខុសគ្នាជាមធ្យមពីថ្លៃកៅស៊ូប្រភេទ TSR20 និងគម្លាតស្តង់ដាររបស់វាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះនៅក្នុងប្រទេសនីមួយៗ ដើម្បីជៀសវាងការរំខាននៅក្នុងមុខងារទីផ្សារជាក់ស្តែង។

*ថ្លៃអប្បបរមាគោល* មិនគួរកំណត់ទាបពេកទេ ដូច្នេះវាជំរុញកសិករឱ្យបន្តសកម្មភាពកសិកម្មរបស់ពួកគេ និងធានាការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាពក្នុងរយៈពេលយូរ។ យ៉ាងណាក៏ដោយ ថ្លៃអប្បបរមាអាចនឹងមិនត្រូវបានកំណត់ខ្ពស់ពេកទេ ព្រោះវាអាចនាំឱ្យមានការដាំដុះច្រើនផ្សេងទៀតដោយការពង្រីកផ្ទៃដីដាំកៅស៊ូក្នុងទ្រង់ទ្រាយធំ។

*ថ្លៃអតិបរមាគោល* ត្រូវបានកំណត់ ដើម្បីកាត់បន្ថយការប្រែប្រួលថ្លៃនៅក្នុងទីផ្សារកៅស៊ូធម្មជាតិ ជាពិសេសតួអង្គក្នុងផ្នែកលំហូរក្រោម ក្នុងការគ្រប់គ្រងថ្លៃដើមក្នុងប្រតិបត្តិការរបស់ពួកគេ។ ប្រសិនបើថ្លៃត្រូវបានកំណត់ខ្ពស់ពេក វាអាចលើកទឹកចិត្តឱ្យតួអង្គឧស្សាហកម្ម ជំនួសកៅស៊ូធម្មជាតិ ដោយវត្ថុធាតុដើមជំនួសផ្សេងទៀតក្នុងរយៈពេលវែង ឬបង្កើនបន្ទុកហិរញ្ញវត្ថុរបស់ខ្លួនលើថ្លៃលទ្ធកម្មខ្ពស់។

### ៥. តើយ៉ាងណាដែរ ថ្លៃអប្បបរមា និងអតិបរមាដែលស្នើឡើងក្នុងយន្តការថ្លៃប្រកបដោយនិរន្តរភាព?

សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) ស្នើឱ្យអនុវត្តយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាពនេះសម្រាប់ប្រភេទកៅស៊ូសំខាន់ៗ។

ចំពោះការចាប់ផ្ដើមយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាពនឹងកំណត់ជាមួយនឹងថ្លៃផ្ទុកទំនិញចូលនាវានូវប្រភេទកៅស៊ូ TSR 20 ដូចតទៅ៖

-ថ្លៃអប្បបរមា៖ ២២០ សេនដុល្លារអាមេរិក ក្នុងមួយគីឡូក្រាម(២ ២០០ដុល្លារអាមេរិក/ តោន)

-ថ្លៃអតិបរមា៖ ៣៥០ សេនដុល្លារអាមេរិក ក្នុងមួយគីឡូក្រាម(៣ ៥០០ដុល្លារអាមេរិក/ តោន)

**Chart: Monthly Movement Chart of TSR-20 price in SGX Futures Market, July 1997 to December 2020**




*Note: The green area above the chart derived for the 220 US cent per kg and 350 US cent per kg set for 2020 and backdated it till 1997 with reference to inflation rate.

### *1 - គំនូសតាង៖ តារាងចលនាប្រចាំខែនៃថ្លៃកៅស៊ូ TSR-20 នៅក្នុង SGX Futures Market ខែកក្កដា ឆ្នាំ 1997 ដល់ខែធ្នូ ឆ្នាំ 2020*

ការពិនិត្យមើលចលនាថ្លៃប្រចាំខែកន្លងមកនៃកិច្ចសន្យាអនាគតកៅស៊ូប្រភេទTSR-20  នៅក្នុងទីផ្សារភាគហ៊ុន Singapore Exchange ចាប់ពីខែកក្កដា ឆ្នាំ១៩៩៧ ដល់ខែធ្នូ ឆ្នាំ២០២០។ ការសង្កេតមួយចំនួនក្នុងអំឡុងពេលយោងនេះត្រូវបានបង្ហាញខាងក្រោម ខណៈពេលដែលយោងទៅលើតារាងខាងលើ។

-មានតែ៣៩ ខែប៉ុណ្ណោះក្នុងចំណោម ២៨២ ខែ ដែលថ្លៃខ្ពស់ជាងថ្លៃអតិបរមា ដែលបានស្នើឡើងនៃយន្តការថ្លៃប្រកបដោយនិរន្តរភាព។

-៥៦ខែ ក្នុងចំណោម២៨២ខែ ដែលថ្លៃស្ថិតនៅចន្លោះថ្លៃអប្បបរមានិងអតិបរមា ដែលបានស្នើឡើង។

-១៨៧ខែ ក្នុងចំណោម ២៨២ខែ ដែលស្មើរតែ ៦៦% នៃរយៈពេលនេះ ដែលថ្លៃទាបជាងថ្លៃអប្បបរមាដែលបានស្នើឡើង។

-ចលនាថ្លៃណាមួយដែលយោងទៅលើកត្តាមូលដ្ឋាន ជាធម្មតាមានអាយុកាលខ្លី បើប្រៀបធៀបទៅនឹងចលនាថ្លៃដែលបណ្តាលមកពីកត្តាមិនមែនមូលដ្ឋាន។ និយាយមួយបែបទៀតគឺថា រយៈពេលថ្លៃទាបហាក់ដូចជាមានរយៈពេលយូរជាង បើប្រៀបធៀបទៅនឹងថ្លៃខ្ពស់។

### ៦.តើរដ្ឋាភិបាលសមាជិកនៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ( ANRPC ) គ្រប់គ្រងយន្តការថ្លៃប្រកបដោយនិរន្តរភាព តែនៅកម្រិតថ្លៃផ្ទុកទំនិញចូលនាវា ( F.O.B ) ឬកម្រិតថ្លៃនៅចម្ការ ( Farm gate ) ទេឬ ?

រដ្ឋាភិបាលសមាជិកសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ANRPC អាចអនុវត្តការកំណត់ថ្លៃទៅតាមយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព ដោយការដាក់ពិន្ទុជាគោលទាំងថ្លៃផ្ទុកទំនិញក្នុងនាវា(F.O.B) ឬកម្រិតថ្លៃនៅចម្ការ (Farm Gate)។ នេះគឺជាគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្រ្តទាំងនេះ។

-នៅក្នុងការគ្រប់គ្រងថ្លៃផ្ទុកទំនិញក្នុងនាវា (F.O.B) វាអាចកាន់តែងាយស្រួលក្នុងការគ្រប់គ្រងវា ព្រោះអ្នកនាំចេញត្រូវការលិខិតអនុញ្ញាតដើម្បីនាំចេញ។ ប្រសិនបើថ្លៃកៅស៊ូដែលស្នើឱ្យនាំចេញធ្លាក់ហួសពីថ្លៃគោលនៃយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាពដែលបានកំណត់ ការអនុញ្ញាតនាំចេញនឹងមិនត្រូវបានផ្តល់ឡើយ។ ជាអកុសល ថ្លៃកៅស៊ូដែលទិញពីចម្ការផ្ទាល់នឹងត្រូវបានកំណត់ដោយអ្នកនាំចេញ ខណៈពេលនៃការទិញកៅស៊ូធម្មជាតិនៅពីកសិករ។

-រដ្ឋាភិបាលនឹងគណនាថ្លៃនៅចម្ការសមស្រប ប្រសិនបើថ្លៃផ្ទុកទំនិញក្នុងនាវា F.O.B. គឺ ២២០សេនដុល្លារអាមេរិកក្នុងមួយគីឡូក្រាម ដោយអនុវត្តកំណត់ត្រានៃភាពខុសគ្នានៃថ្លៃក្នុងប៉ុន្មានឆ្នាំកន្លងមក និងគម្លាតស្តង់ដាររបស់វា ឧទាហរណ៍ ប្រសិនបើភាពខុសគ្នានៃថ្លៃផ្ទុកទំនិញចូលនាវា (F.O.B) និងថ្លៃនៅចម្ការ (Farm Gate) នៅក្នុងប្រទេស A គឺ ៣៥សេនដុល្លារអាមេរិក ដូច្នេះថ្លៃនៅចម្ការ Farm Gate គួរតែត្រូវបានគ្រប់គ្រងនៅ១៨៥ សេនដុល្លារអាមេរិក ហើយប្រសិនបើភាពខុសគ្នានៃថ្លៃផ្ទុកទំនិញក្នុងនាវា (F.O.B) និងថ្លៃនៅចម្ការ (Farm Gate) នៅក្នុងប្រទេស B គឺ ៥០សេនដុល្លារអាមេរិក នោះថ្លៃថ្លៃនៅចម្កា (Farm Gate) គួរតែត្រូវបានគ្រប់គ្រងនៅ ១៧០សេនដុល្លារអាមេរិក។

-នៅក្នុងការគ្រប់គ្រ**ថ្លៃនៅចម្ការ** (Farm Gate) កសិករនឹងត្រូវបានធានាយ៉ាងពិតប្រាកដសម្រាប់ការលក់របស់ពួកគេក្នុងតម្លៃគោលដៅ។ កសិករនឹងត្រូវបានគេជូនដំណឹង ហើយអាចដាក់ពាក្យបណ្តឹងទៅអាជ្ញាធរប្រសិនបើអ្នកទិញណាមួយផ្តល់ជូន ឬទិញក្រោមថ្លៃគោលដៅ និងផ្ទុយពីនេះ។

## ៧. តើនាគីពាក់ព័ន្ធកៅស៊ូអាចផ្តល់ការទិញ ឬលក់លើសពីថ្លៃដែលបានស្នើឡើងដែរឬទេ?

ការអនុវត្ត SPM ដែលស្មើនឹងត្រូវបានអនុវត្តដោយប្រទេសផលិតកៅស៊ូធម្មជាតិរៀងៗខ្លួន ហើយវាអាចប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ។ នៅក្នុងប្រទេសមួយចំនួន វាអាចជាទម្រង់នៃច្បាប់ ឬបទ-ប្បញ្ញត្តិនៅក្នុងទីផ្សារក្នុងស្រុក។ ឈ្មួញណាមួយដែលផ្តល់តម្លៃទិញ ឬលក់លើសពីតម្លៃគោលដៅ ទាំងតម្លៃអប្បបរមា ឬអតិបរមា ត្រូវបានគេចាត់ទុកថាបំពានច្បាប់ ឬបទប្បញ្ញត្តិ ហើយត្រូវទទួលរងការផាកពិន័យតាមច្បាប់ ឬបទប្បញ្ញត្តិនៅក្នុងប្រទេសរៀងៗខ្លួន។ នៅក្នុងប្រទេសផ្សេងទៀត នេះអាចជាយន្តការផ្សេងទៀត ដូចជាថ្លៃដែលបានកំណត់រវាងអ្នកទិញ និងអ្នកលក់ ដើម្បីឱ្យស្ថិតក្នុងកម្រិតថ្លៃអប្បបរមា ឬអតិបរមា។

## ៨.តើនាគីពាក់ព័ន្ធកៅស៊ូត្រូវបានផ្តល់រយៈពេលអនុគ្រោះណាមួយ ដើម្បីកែសម្រួលការសម្រេចចិត្តការធ្វើធុរៈកិច្ចរបស់ខ្លួនមុនកាលបរិច្ឆេទនៃការអនុវត្តលើយន្តការថ្លៃប្រកបដោយនិរន្តរភាព ដែរឬទេ?

បាទ/ចាស រយៈពេលអនុគ្រោះមានពី ៣ ទៅ ៥ខែ ត្រូវបានផ្តល់ឱ្យអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងពាណិជ្ជករក្នុងស្រុក អ្នកនាំចេញ ក៏ដូចជាក្រុមហ៊ុនផលិត ដើម្បីធ្វើការកែតម្រូវចាំបាច់។

អ្នកចូលរួមនៅក្នុងកិច្ចសន្យាទីផ្សារដោយផ្ទាល់ ត្រូវបានពិចារណាចាប់តាំងពីកាលបរិច្ឆេទចែកចាយរបស់ពួកគេជារឿយៗតិចជាងពីរខែក្នុងតម្លៃថេរ។ ពួកគេអាចចំណេញ/ខាតពីការអនុវត្តយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព ប្រសិនបើថ្លៃផ្លាស់ប្តូរ ឬកែតម្រូវលឿនជាងពី៣-៥ខែ។

ខណៈដែលកិច្ចសន្យារយៈពេលវែង ការកំណត់ថ្លៃដោយផ្អែកលើទីផ្សារអនាគត ជាធម្មតាផ្តល់ជូនមួយខែមុនខែប្រគល់-ទទួល។ ជាលទ្ធផល វានឹងមិនរងផលប៉ះពាល់ពីការអនុវត្តយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព SPM នេះទេ។

## ៩. មូលដ្ឋានសម្រាប់ការអនុវត្តយន្តការថ្លៃប្រកបដោយនិរន្តរភាព

ថ្លៃអប្បបរមាដោយការប្រៀបធៀបទៅនឹងថ្លៃផ្ទុកទំនិញចូលនាវា (F.O.B) កៅស៊ូប្រភេទ TSR20 នៅតម្លៃ ២២០សេនដុល្លារអាមេរិកក្នុងមួយគីឡូក្រាម (២២០០ដុល្លាអាមេរិក/តោន) គឺមិនខ្ពស់ពេកនិងមានគ្រោះថ្នាក់ដល់ការធ្វើធុរៈកិច្ចកៅស៊ូធម្មជាតិផ្នែលលំហូរក្រោម ដោយគិតថាថ្លៃជាមធ្យមក្នុងរយៈពេល២ឆ្នាំ ក្នុងឆ្នាំ 2011-2012 គឺ ៤០០ សេនដុល្លារអាមេរិកក្នុងមួយគីឡូក្រាម (៤០០០ដុល្លាអាមេរិក/តោន) ។ ជាងនេះទៅទៀត ការប្រែប្រួលថ្លៃខ្ពស់ក្នុងកំឡុងពេលយោងបានបង្កបញ្ហាប្រឈមក្នុងផ្នែកលំហូរក្រោម ជាពិសេសក្នុងការគ្រប់គ្រងមូលធន។

ជាលទ្ធផល  គោលដៅចុងក្រោយនៃយន្តការនេះគឺដើម្បីបង្កើតបរិយាកាសសមស្រប  និងលើកទឹកចិត្តឱ្យមានកំណើនរយៈពេលវែងនៅក្នុងខ្សែច្រវ៉ាក់តម្លៃនៃឧស្សាហកម្មកៅស៊ូធម្មជាតិ   ដែលជាវិធីសាស្ត្រឈ្នះៗសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ ។

## សូមមេត្តាចុចដំណរភ្ជាប់ខាងក្រោមនេះ  ដើម្បីឆ្លើយនឹងសំណួរទាក់ទងពីសេចក្តីសង្ខេបអំពីការស្នើយន្តការថ្លៃកៅស៊ូប្រកបដោយនិរន្តរភាព (SMP)

https://forms.office.com/pages/responsepage.aspx?id=ZrM32VS_ZUmoQ7uxrt-cXkBGkAuihE9Is963d51cQ9pUNUM0QTZURjJCQ1dZTVIxWVZMSVk5UzBVVyQlQCN0PWcu